រាជបណ្ឌិត្យសភាកម្ពុជា

# «ទស្សនទានស្តីពីមីក្រូសហគ្រាស សហគ្រាសធុនតូចនិងមធ្យម នៅប្រទេសកម្ពុជា»

ដោយ បណ្ឌិត ព្រុំ ទេវី

អនុប្រធានវិទ្យាស្ថានសង្គមសាស្ត្រ និងវិទ្យាសាស្ត្រសង្គម

*ខែមករា ឆ្នាំ២០១៩*

# ទស្សនទានស្តីពីមីក្រូសហគ្រាស សហគ្រាសធុនតូចនិងមធ្យម នៅប្រទេសកម្ពុជា

ដោយ បណ្ឌិត ព្រុំ ទេវី
អនុប្រធានវិទ្យាស្ថានសង្គមសាស្ត្រ និងវិទ្យាសាស្ត្រសង្គម

ក្របខណ្ឌគោលនយោបាយសម្រាប់ការអភិវឌ្ឍន៍មីក្រូសហគ្រាស សហគ្រាសធុនតូចនិងមធ្យម ( Micro Small and Medium Enterprises: MSMEs ) ទើបតែបានបង្កើតនៅកម្ពុជាក្នុងទសវត្សរ៍ទី៩០ប៉ុណ្ណោះ។ MSMEs មានតួនាទីជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចរបស់កម្ពុជាដែលបំពេញតម្រូវការមូលដ្ឋាននៃទំនិញនិងសេវាកម្មក៏ដូចជាការរួមចំណែកដល់ការលើកកម្ពស់ជីវភាពរស់នៅនិងកាត់បន្ថយភាពក្រីក្រ។ សហគ្រាសបែបនេះមានជាង៩០%នៃសហគ្រាសសរុបនៅកម្ពុជា និងចូលរួមចំណែកយ៉ាងសំខាន់ក្នុងការផលិតនិងផ្តល់សេវានៅក្នុងប្រទេស។ វត្តមាននៃ MSMEs នៅកម្ពុជា បានផ្តល់ឱកាសការងារសម្រាប់ប្រជាជនក្នុងប្រទេសគ្រប់ទិសទី ជាពិសេសនៅតាមទីជនបទដាច់ស្រយាល និងធ្វើប្រសើរឡើងផងដែរនូវការបែងចែកប្រាក់ចំណូល។ MSMEs ក៏បានរួមចំណែកក្នុងការបង្កើតថ្មី បង្កើនផលចំណូលសរុបក្នុងស្រុក ក៏ដូចជាជំរុញការនាំចេញជាដើម។

ក្នុងដំណើរការគ្រប់គ្រងនិងអភិវឌ្ឍន៍នៃវិស័យនេះ ប្រទេសកម្ពុជានៅមានបញ្ហាជាច្រើន ព្រោះ MSMEs មានទាំងនៅក្នុងវិស័យផ្លូវការ ទាំងមិនផ្លូវការ។ ដោយសារភាពខ្វះចន្លោះនៃការគ្រប់គ្រងនេះហើយដែលធ្វើឱ្យ MSMEs មានការលំបាកដើម្បីទទួលបាននូវប្រាក់កម្ចី ការធ្វើឱ្យប្រសើរឡើងបំណិនសហគ្រិនភាពនិងគ្រប់គ្រងទទួលបាននូវបច្ចេកវិទ្យាថ្មី ទីផ្សារក្នុងនិងក្រៅប្រទេសសម្រាប់ទំនិញនិងសេវារបស់ខ្លួន។ល។

អត្ថបទនេះនឹងបង្ហាញពីសារៈតា ការកំណត់និយមន័យ និងបញ្ហាពាក់ព័ន្ធមួយចំនួនក្នុងការគ្រប់គ្រងនិងអភិវឌ្ឍន៍ MSMEsនៅកម្ពុជា។

## ១- ប្រវត្តិសហគ្រាសធុនតូចនិងមធ្យមនៅប្រទេសកម្ពុជា

បន្ទាប់ពីទទួលបានឯករាជ្យពីបារាំងក្នុងឆ្នាំ១៩៥៤ វិស័យសហគ្រាសឧស្សាហកម្មធុនតូចនិងមធ្យមនៅកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់។ ប្រមាណជានៅឆ្នាំ១៩៥៥ មានសហគ្រាសធុនតូចនិងមធ្យមចំនួន៣៦៩

ដែលបានចុះបញ្ជី ដល់ឆ្នាំ១៩៥៨ មានចំនួនជាង១០០០។ ក្នុងនោះមានរោងចក្រដំឡើងរថយន្ត ម៉ូតូ ម៉ាស៊ីនដេរ រោងចក្រតម្បាញ រោងចក្រផលិតសាប៊ូ ក្រដាស ស្ករស និងត្រីខកំប៉ុង[1]។

ក្នុងអំឡុងការគ្រប់គ្រងរបស់របបខ្មែរក្រហមពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ សហគ្រាសទាំងអស់ត្រូវបានបិទទ្វារ ហើយការលក់ដូរនៅទីផ្សារនិងការប្រើប្រាស់ប្រាក់កាសត្រូវបានចាត់ទុកថាជាទង្វើខុសច្បាប់។ ក្រោយជ័យជំនះថ្ងៃទី៧ មករា ឆ្នាំ១៩៧៩ លើរបបខ្មែរក្រហម MSMEs នៅកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់។ នាដើមទសវត្សរ៍ទី៨០ មានការចាប់ផ្តើមសកម្មភាពជាក្រុមតូចៗក្នុងការផលិតស្រូវ ដើម្បីបំពេញតម្រូវការជាមូលដ្ឋានរបស់ប្រជាជនកម្ពុជា។ ក្រុមតូចៗទាំងនោះមានឈ្មោះថា *ក្រុមសាមគ្គី* ក្នុងមួយក្រុមៗមានការចូលរួមប្រមាណជា១០ទៅ១៥គ្រួសារ ដើម្បីរួមគ្នា សហការគ្នាក្នុងការដាំដំណាំស្រូវ។ គ្រួសារនីមួយៗចូលរួមជាកម្លាំងពលកម្ម ជានង្គ័ល រនាស់ ឬជាកម្លាំងអូសទាញ(គោឬក្របី) ដីស្រែ ហើយទទួលផលទៅតាមការព្រមព្រៀងគ្នានិងបែកចែកទៅតាមអ្វីដែលគេបានដាក់ចូលរួម។ ក្រុមសាមគ្គីទាំងនេះធ្វើការជាលក្ខណៈសហករណ៍ ហើយស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាល។

ឆ្នាំ១៩៨០ ប្រទេសកម្ពុជាចាប់ផ្តើមមានការប្រើប្រាស់ក្រដាសប្រាក់ឡើងវិញ ហើយ MSMEs ក៏ចាប់ផ្តើមកកើតឡើងក្នុងវិស័យឯកជនក្នុងការកែច្នៃម្ហូបអាហារដូចជាសិប្បកម្មផលិតទឹកត្រី ស្ករសជាដើម ដើម្បីបំពេញតម្រូវការក្នុងស្រុក។ ចុងឆ្នាំ១៩៨៩ MSMEs របស់រដ្ឋត្រូវបានលក់ទៅឱ្យខាងវិស័យឯកជនជាបន្តបន្ទាប់ ចាប់ពីឆ្នាំ១៩៩៣មក កម្ពុជាចាប់ផ្តើមកសាងប្រទេសតាមបែបសេដ្ឋកិច្ចទីផ្សារសេរីយ៉ាងពេញលេញ។

ស្ថិតក្នុងស្ថានភាពអំណោយផលពីការដាក់ចេញនូវនយោបាយឈ្នះ-ឈ្នះចាប់តាំងពីឆ្នាំ១៩៩៨ និងការអនុវត្តន៍គោលនយោបាយសេដ្ឋកិច្ចប្រកបដោយប្រសិទ្ធភាពរបស់រាជរដ្ឋាភិបាលក្រោមការរក្សាបានសុខសន្តិភាព និងស្ថិរភាពនយោបាយ កម្ពុជារក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចយ៉ាងរឹងមាំ។ ជាមួយគ្នានេះដែរ MSMEs ក៏បានចូលរួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយតុល្យភាពនិងបរិយាបន្ន។

## ២- និយមន័យនៃពាក្យ មីក្រូសហគ្រាស សហគ្រាសខ្នាតតូច និងមធ្យមនៅកម្ពុជា

និយមន័យរបស់MSMEs អាចប្រែប្រួលពីប្រទេសមួយទៅប្រទេសមួយអាស្រ័យលើវិស័យដែលពាក់ព័ន្ធ និងមិនមានលក្ខណៈជាសកលទេ ប្រែប្រួលទៅតាមប្រទេស និងវិស័យដែលគេត្រូវសិក្សា។ ប្រទេសខ្លះបែងចែកតាមចំនួននិយោជិត ទ្រព្យរបស់ក្រុមហ៊ុន ហើយខ្លះទៀតផ្អែកទៅលើទំហំនៃផលចំណូលសរុបប្រចាំឆ្នាំ។ សម្រាប់លក្ខណៈវិនិច្ឆ័យចុងក្រោយ[2] ប្រទេសភាគច្រើនប្រើរូបិយប័ណ្ណក្នុងស្រុក។ ក្នុងករណីដែលតម្លៃរូបិយប័ណ្ណត្រូវបាន

---

[1] Baily, P. (2008): Cambodian Small and Medium Sized Enterprises, Constraints, Policies and Proposals for Their Development. In: Lim, H.(ed.), SME in Asia and Globalization, ERIA Research Project Report 2007

[2] https://www.unescap.org/sites/default/files/7 - SMEs IN ASIA AND THE PACIFIC.pdf. Retrieved on 06-09-2018.

គិតចំពោះទ្រព្យសម្បត្តិឬផលចំណូល អតិផរណាអាចជាមូលហេតុនាំឱ្យមានបញ្ហាសម្រាប់និយមន័យរបស់ MSMEs។

រហូតមកដល់ឆ្នាំ២០០៥ ប្រទេសកម្ពុជាមិនទាន់មានចំណាត់ថ្នាក់ជាផ្លូវការសម្រាប់ MSMEs ទេ។ វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការបានចាត់ចំណាត់ថ្នាក់សហគ្រាសដែលមានបុគ្គលិកតិចជាង១០នាក់ជាសហគ្រាសខ្នាតតូចមានចំនួន១១នាក់ឬច្រើនជាងនេះជាសហគ្រាសខ្នាតធំ បន្ទាប់មកក៏មានការចាត់ថ្នាក់ថា សហគ្រាសដែលមាននិយោជិតពី១១ ទៅដល់១០០នាក់ ជាសហគ្រាសខ្នាតមធ្យមផងដែរ។ ស្របពេលជាមួយគ្នានេះ ក្រសួងឧស្សាហកម្មរ៉ែនិងថាមពល បានកំណត់សហគ្រាសខ្នាតតូចមានបុគ្គលិកតិចជាង៥០នាក់។

ក្រសួងមួយចំនួនប្រើនិយមន័យមួយឬទាំងពីរនេះ ខណៈពេលដែលអ្នកផ្សេងទៀតប្រើនិយមន័យផ្សេងគ្នាអាស្រ័យលើមូលដ្ឋាននៃតម្លៃទ្រព្យសកម្ម។ នេះធ្វើឱ្យវាមានការលំបាកក្នុងការប្រៀបធៀបទិន្នន័យ MSMEs ពីប្រភពផ្សេងៗគ្នា ហើយនៅពេលដែលនិយមន័យត្រូវបានផ្លាស់ប្តូរពីមួយដំណាក់កាលមួយទៅដំណាក់កាលមួយបន្ទាប់ទៀត។ នៅខែកក្កដាឆ្នាំ២០០៥ អនុគណៈកម្មាធិការសហគ្រាសធុនតូច និងមធ្យមកម្ពុជា បានស្នើការចាត់ថ្នាក់ខាងក្រោម៖

**តារាងទី១: និយមន័យ MSMEs នៅកម្ពុជា**

| ចំណាត់ថ្នាក់ | បុគ្គលិក (នាក់) | ទ្រព្យសកម្ម (មិនរាប់បញ្ចូលដី និងគិតជាដុល្លារអាម៉េរិក) |
|---|---|---|
| **មីក្រូសហគ្រាស** | < ១០ | < ៥0 000 |
| **សហគ្រាសធុនតូច** | ១១-៥០ | ៥0,000-២៥0,000 |
| **សហគ្រាសធុនមធ្យម** | ៥១-១00 | ២៥0,000-៥00,000 |
| **សហគ្រាសធុនធំ** | > ១00 | > ៥00,000 |

(**ប្រភព៖** រាជរដ្ឋាភិបាលកម្ពុជា, អនុគណៈកម្មាធិការសហគ្រាសធុនតូចនិងមធ្យម: ក្របខណ្ឌគោលនយោបាយសម្រាប់ការអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យមខ្នាតតូច ថ្ងៃទី២៩ ខែ កក្កដា ឆ្នាំ២០០៥, ទំព័រទី១៣)

ប្រទេសកម្ពុជា គឺជាករណីលើកលែងមួយដែលក្នុងនោះនិយមន័យរបស់ខ្លួនប្រើប្រាក់ដុល្លារអាម៉េរិក មិនមែនជាប្រាក់រៀលទេ។ សម្រាប់ការរៀបចំគោលនយោបាយនិងស្ថិតិ និយមន័យត្រូវបានផ្អែកលើចំនួនបុគ្គលិកនៅពេលចំនួនបុគ្គលិកមិនសមស្រប ការកំណត់និយមន័យត្រូវផ្អែកលើទ្រព្យសកម្ម[3]។

គួរកត់សម្គាល់ផងដែរថា ចំណាត់ថ្នាក់ MSMEs ខាងលើគ្របដណ្តប់តែវិស័យឧស្សាហកម្មនិងសិប្បកម្មប៉ុណ្ណោះ ដោយសារអនុគណៈកម្មាធិការសហគ្រាសធុនតូចនិងមធ្យម គឺជាផ្នែកមួយនៃក្រសួងឧស្សាហកម្មនិង

[3] រាជរដ្ឋាភិបាលកម្ពុជា, អនុគណៈកម្មាធិការសហគ្រាសធុនតូចនិងមធ្យម ២០០៥

សិប្បកម្ម។ សម្រាប់គោលបំណងប្រមូលពន្ធ រាជរដ្ឋាភិបាលកម្ពុជាបានចេញ អនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីអំពីពន្ធលើសហគ្រាសធុនតូចនិងមធ្យម[4] និងបានផ្តល់និយមន័យនៃសហគ្រាសខ្នាតតូចនិងមធ្យមដូចខាងក្រោម៖

- សហគ្រាសខ្នាតតូច គឺជាសហគ្រាសដែលមានចំណូលប្រចាំឆ្នាំពី២៥០លាន ទៅ ៧០០លានរៀល
- សហគ្រាសខ្នាតមធ្យម គឺជាសហគ្រាសដែលមានចំណូលប្រចាំឆ្នាំពី៧០០លានរៀល ទៅ ២០០០លានរៀល។

តាមទស្សនៈនេះការចាត់ថ្នាក់មិនត្រឹមតែគ្របដណ្តប់លើឧស្សាហកម្មនិងសិប្បកម្មប៉ុណ្ណោះទេ ថែមទាំងសម្រាប់គ្រប់វិស័យផងដែរ។ ម៉្យាងទៀត រាជរដ្ឋាភិបាលកម្ពុជាបានចាប់ផ្តើមប្រើប្រាស់ប្រាក់រៀលក្នុងការបែងចែកសហគ្រាសក៏ដូចជានៅប្រទេសផ្សេងទៀតដែលប្រើរូបិយវត្ថុរបស់គេផ្ទាល់ដែរ។

លើសពីនេះទៅទៀត នៅក្នុងការធ្វើចន្លោះជំរឿនសហគ្រាសឆ្នាំ២០១៤ របស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ការកំណត់និយមន័យរបស់សហគ្រាសធុនតូចនិងមធ្យមពីអនុគណៈកម្មាធិការ សហគ្រាសធុនតូចនិងមធ្យមត្រូវបានប្រើប្រាស់ ដោយសារមិនមាននិយមន័យផ្សេងៗពីក្រសួងដទៃទៀតទេ។

នៅខែកញ្ញា ឆ្នាំ២០១៨ ក្រុមប្រឹក្សាជាតិភាសាខ្មែរ បានកំណត់ចំណាត់ថ្នាក់ថ្មីនៃសហគ្រាសធុនតូចនិងមធ្យមដែលរួមបញ្ចូលចំណាត់ថ្នាក់ពីអនុគណៈកម្មាធិការសហគ្រាសធុនតូចនិងមធ្យម និងរាជរដ្ឋាភិបាលកម្ពុជាដែលក្នុងនោះមានការប្តូរការប្រើប្រាក់ដុល្លារអាម៉េរិក មកជាប្រាក់រៀល ដោយគិតអត្រា១ដុល្លារអាម៉េរិច ស្មើនឹង ៤០០០រៀល។

ខែតុលា ឆ្នាំ២០១៨ រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យលេខ១២៤ អនក្រ.បក ស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារ សម្រាប់សហគ្រាសធុនតូច និងមធ្យមជាថ្មីម្តងទៀត។ ក្នុងមាត្រាទី៤នៃអនុក្រឹត្យនេះ ក៏បានកែសម្រួលនិយមន័យសហគ្រាសធុនតូច និងមធ្យម[5] ដែលនៅក្នុងនោះធ្វើឱ្យសហគ្រាសមួយចំនួនធំបានផ្លាស់ប្តូរចំណាត់ថ្នាក់របស់ខ្លួនពីសហគ្រាសធុនធំ មកជាសហគ្រាសធុនមធ្យម ពីធុនមធ្យមទៅតូច ក៏ដូចជាពីធុនតូចទៅមីក្រូសហគ្រាសនេះបើគិតតាមការកំណត់ផលចំណូល។សូមបញ្ជាក់ផងដែរថា អនុក្រឹត្យចុងក្រោយនេះរបស់រាជរដ្ឋាភិបាល ក៏មានបញ្ជាក់ពីចំនួននិយោជិតតាមប្រភេទសហគ្រាសផងដែរ ហើយដូចគ្នានឹងការកំណត់របស់អនុគណៈកម្មាធិការសហគ្រាសធុនតូចនិងមធ្យមពីមុនមកដែរ។

---

[4] រាជរដ្ឋាភិបាលកម្ពុជា៖ អនុក្រឹត្យលេខ១៧អនក្រ.បក ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការលើទឹកចិត្តផ្នែកពន្ធដារចំពោះការចុះបញ្ជីដោយស្ម័គ្រចិត្តរបស់សហគ្រាសធុនតូចនិងសហគ្រាសធុនមធ្យម។

[5] បើប្រៀបធៀបជាមួយនឹងអនុក្រឹត្យលេខ១៧អនក្រ.បក ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការលើទឹកចិត្តផ្នែកពន្ធដារចំពោះការចុះបញ្ជីដោយស្ម័គ្រចិត្តរបស់សហគ្រាសធុនតូចនិងសហគ្រាសធុនមធ្យម។

*សហគ្រាសធុនតូច សំដៅដល់សហគ្រាសអាជីវកម្មគ្រប់ប្រភេទដែលមានផលរបរប្រចាំឆ្នាំចាប់ពី២៥០លានរៀលដល់៧០០លានរៀល ឬសហគ្រាសដទៃទៀតដែលជាកម្មវត្ថុនៃការចុះបញ្ជីពន្ធដារជាអ្នកជាប់ពន្ធតូចស្របតាមច្បាប់និងបញ្ញត្តស្តីពីពន្ធដារ ឬមានចំនួននិយោជិតចាប់ពី១០ទៅ៥០នាក់។*

*សហគ្រាសធុនមធ្យម សំដៅដល់សហគ្រាសអាជីវកម្មគ្រប់ប្រភេទដែលមានផលរបរប្រចាំឆ្នាំចាប់ពី៧០០លានរៀលដល់៤០០០លានរៀល ឬសហគ្រាសដទៃទៀតដែលជាកម្មវត្ថុនៃការចុះបញ្ជីពន្ធដារជាអ្នកជាប់ពន្ធតូចស្របតាមច្បាប់និងបញ្ញត្តស្តីពីពន្ធដារ ឬមានចំនួននិយោជិតចាប់ពី៥១ទៅ១០០នាក់។*

ជាសរុបមក គិតមកត្រឹមដំណាច់ឆ្នាំ២០១៨នេះ យើងបាននិយមន័យ MSMEs នៅកម្ពុជាដូចក្នុងតារាងទី២ខាងក្រោមនេះ៖

**តារាងទី២៖ និយមន័យ MSME នៅកម្ពុជា**

| ចំណាត់ថ្នាក់ | បុគ្គលិក (នាក់) | ទ្រព្យសកម្ម (មិនរាប់បញ្ចូលដីនិងប្រាក់លានរៀល) | ចំណូលប្រចាំឆ្នាំ (លានរៀល) |
|---|---|---|---|
| **មីក្រូសហគ្រាស** | < ១០ | < ២០០ | < ២៥០ |
| **សហគ្រាសធុនតូច** | ១០-៥០ | ចាប់ពី ២០០- តិចជាង ២៥០ | ចាប់ពី ២៥០-តិចជាង៧០០ |
| **សហគ្រាសធុនមធ្យម** | ៥១-១០០ | ចាប់ពី ២៥០-២០០០ | ចាប់ពី ៧០០-តិចជាង ២០០០ |
| **សហគ្រាសធុនធំ** | > ១០០ | > ២០០០ | > ២០០០ |

(ប្រភព៖ ប្ញូកសរុបដោយអ្នកនិពន្ធ)

## ៣- តួនាទីរបស់មីក្រូសហគ្រាស សហគ្រាសធុនតូចនិងមធ្យមក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចនៃប្រទេសកម្ពុជានិងបញ្ហាប្រឈម

MSMEs នៅកម្ពុជាក៏ដូចជាមានតួនាទីយ៉ាងសំខាន់ក្នុងការ៖ ក) បង្កើតការងារ ខ) បង្កើតប្រាក់ចំណូលសម្រាប់ប្រជាជនដែលមានចំណូលទាប និងប្រជាជនដែលងាយរងគ្រោះ និងគ) ជំរុញកំណើនសេដ្ឋកិច្ចស្ថិរភាពសង្គមនិងរួមចំណែកដល់កំណើនវិស័យឯកជនប្រកបដោយថាមពល។

លោក Uchikawa និង Keola បានបែងចែក MSMEs ក្នុងប្រទេសកម្ពុជា វៀតណាម និងឡាវ ជា៤ក្រុមធំៗ[6]គឺ៖ ក) ក្រុមអ្នកផ្គត់ផ្គង់ឧស្សាហកម្ម ខ) ក្រុមឧស្សាហកម្មសម្រាប់ការនាំចេញ គ) ក្រុមអ្នកផ្គត់ផ្គង់ទីផ្សារក្នុងស្រុក និងឃ) មីក្រូសហគ្រាស។ MSMEsដែលជាអ្នកផ្គត់ផ្គង់ដល់វិស័យឧស្សាហកម្ម មានទំនាក់ទំនងជាមួយគ្នា

[6] Uchikawa, S. and Keola, S. : Small and Medium Enterprises in Cambodia, Laos, and Vietnam. In: Kuchiki, A. and S. Uchikawa (eds.), Research on Development Strategies for CLMV Countries. ERIA Research Project Report 2008-5, pp.237-273, Jakarta, ERIA.

តាមរយៈការផ្គត់ផ្គង់មធ្យោបាយដឹកជញ្ជូន គ្រឿងម៉ាស៊ីននិងគ្រឿងបន្លាស់នានា។ MSMEs ក៏អាចផ្តល់សេវាដឹកជញ្ជូនវត្ថុធាតុដើមនិងផលិតផលសម្រេចរបស់វិស័យឧស្សាហកម្មដែរ។

ឧស្សាហកម្មអតិពលកម្មសម្រាប់ការនាំចេញដូចជាសម្លៀកបំពាក់ និងស្បែកជើងត្រូវបានបង្កើតឡើងនៅក្នុងប្រទេសកម្ពុជា។ កម្មករដែលបម្រើការក្នុងវិស័យនេះ មានតម្រូវការអាហារ ជម្រក សម្លៀកបំពាក់ សេវាកម្មធ្វើដំណើរ និងផលិតផលផ្សេងៗទៀត MSMEs មានតួនាទីជាអ្នកផ្គត់ផ្គង់។

ខណៈពេលដែលសេដ្ឋកិច្ចរីកចម្រើននិងគុណភាពជីវិតកាន់តែប្រសើរ តម្រូវការប្រចាំថ្ងៃដូចជាម្ហូបអាហារ សម្លៀកបំពាក់ និងរបស់របរប្រើប្រាស់ក្នុងផ្ទះសម្បែង ក៏អាចត្រូវបានពង្រីកផងដែរ។ MSMEs មានតួនាទីផលិតផលិតផលទាំងនេះសម្រាប់បំពេញតម្រូវការទីផ្សារក្នុងប្រទេស។ ទីផ្សារប្រភេទនេះមិនត្រូវការស្តង់ដារគុណភាពអន្តរជាតិអ្វីទេ ដូចនេះ MSMEs អាចចូលទីផ្សារបានយ៉ាងងាយស្រួល។

មីក្រូសហគ្រាសនៅប្រទេសកម្ពុជា មានតួនាទីមិនត្រឹមតែផលិតទំនិញ និងផ្តល់សេវាដល់ទីផ្សារប៉ុណ្ណោះទេ តែសហគ្រាសទាំងនេះភាគច្រើនប្រើវិធីសាស្ត្រផលិតតាមបែបប្រពៃណី ការកែច្នៃម្ហូបអាហារ ផលិតឧបករណ៍ប្រើប្រាស់ប្រចាំថ្ងៃ វត្ថុអនុស្សាវរីយ៍ និងគ្រឿងអលង្ការជាដើម។ តាមរយៈនេះ មីក្រូសហគ្រាសមិនត្រឹមតែជាអ្នកបង្កើតការងារបន្ថែមនិងជួយបង្កើនប្រាក់ចំណូលដល់អ្នកនៅតាមតំបន់ជនបទទេ តែបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងថែរក្សាវិធីសាស្ត្រផលិតតាមបែបប្រពៃណី និងធ្វើឱ្យអ្នកប្រើប្រាស់ផលិតផលរបស់គេស្គាល់ពីប្រពៃណីរបស់ខ្មែរយើងទៀតផង។

ដោយសារ MSMEs បានដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច រាជរដ្ឋាភិបាលកម្ពុជាបានធ្វើជំរឿនសេដ្ឋកិច្ចដំបូងរបស់ប្រទេសកម្ពុជាក្នុងឆ្នាំ ២០១១ ហើយត្រូវបានដាក់ឱ្យដំណើរការកាលពីឆ្នាំ២០១២ ហើយក្នុងឆ្នាំ២០១៤ ក៏មានការធ្វើចន្លោះជំរឿនម្តងទៀត។ ជាលទ្ធផលយើងឃើញថា ប្រទេសកម្ពុជាមាន MSMEs ចំនួន ៩៩,៨%នៃសហគ្រាសទាំងអស់នៅក្នុងប្រទេសដែលមានចំនួនសរុប ៥១៣ ៧៦០ ហើយត្រូវបានគេបែងចែកជាមីក្រូសហគ្រាសចំនួន៥០១ ៦១២; សហគ្រាសធុនតូចនិងមធ្យម ១១ ២៥៩ និងសហគ្រាសធុនធំចំនួន៨៨៩។

មីក្រូសហគ្រាសចំនួន៦០,៧%ជាអ្នកលក់ដុំនិងរាយ បន្ទាប់មកក្នុងផ្នែកផលិតកម្មមានចំនួន១៤,0% និងជាអ្នកផ្តល់សេវាកម្មម្ហូបអាហារ និងស្នាក់នៅមានចំនួន១០,៩%។ ចំពោះវិស័យអប់រំវិញមានភាគចំណែកធំនៅក្នុងសហគ្រាសធុនតូច និងមធ្យម៣៣,៧% បន្ទាប់មកគឺផ្នែកផលិតកម្មមាន១៣,៥%។ ក្នុងចំណោមសហគ្រាសធុនធំផ្នែកផលិតកម្មមានចំណែកធំជាងគេគឺ ៤៧,៤% បន្ទាប់មកគឺផ្នែកអប់រំមាន១៦,១%។ ទន្ទឹមនឹងនេះភាគច្រើនមីក្រូសហគ្រាសដែលមានបុគ្គលិកតែ១នាក់ (៣៣%នៃសហគ្រាសសរុប) ឬ ២នាក់ (៤០,៨%នៃសហគ្រាសសរុប)

និងមានទីតាំងតែមួយកន្លែងប៉ុណ្ណោះ (សូមមើលតារាងទី៣)។ ក្នុងចំណោម MSMEs ទាំងអស់ ស្ត្រីជាម្ចាស់ មានចំនួន៦១% ហើយ៩៩%នៃសហគ្រាសទាំងអស់គ្រប់គ្រងដោយជនជាតិកម្ពុជា[7]។

**តារាងទី៣ : ចំនួនសហគ្រាសតាមទំហំនិងទីតាំង (គិតជាភាគរយ)**

| | សហគ្រាសធុនធំ | សហគ្រាសធុនមធ្យមនិងតូច | មីក្រូសហគ្រាស |
|---|---|---|---|
| **ទីតាំងទោល** | ៦៣,១ | ៨៦,០ | ៩៩,២ |
| **ទីស្នាក់ការកណ្តាល** | ១២,១ | ០,៧ | ០,០ |
| **ទីតាំងសាខា** | ២៥,០ | ១៣,៣ | ០,៨ |
| **សរុប** | ១០០ | ១០០ | ១០០ |

(ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ៖ ការអង្កេតចន្លោះសេដ្ឋកិច្ចកម្ពុជា ២០១៤, ភ្នំពេញ ២០១៥ )

ភាគច្រើននៃមីក្រូសហគ្រាស សហគ្រាសធុនតូច និងមធ្យម បានអនុញ្ញាតឱ្យដំណើរការដោយក្រសួងពាក់ព័ន្ធនៅថ្នាក់ស្រុក ឬក្រុង និងគ្រប់គ្រងដោយអាជ្ញាធរមូលដ្ឋាន។ សម្រាប់ម្ចាស់អាជីវកម្មភាគច្រើនពួកគេមានភាពមិនច្បាស់លាស់អំពីអ្វីដែលជាការចុះឈ្មោះស្របច្បាប់នៃអាជីវកម្មរបស់ពួកគេទេ ហើយពួក៏មិនបានដឹងពីនីតិវិធីនៃការចុះបញ្ជីផ្លូវការដែរ។ គេគិតថាពន្ធអាករប្រចាំខែទោះជាផ្លូវការក្តីឬមិនផ្លូវការក្តីជាភស្តុតាងនៃភាពស្របច្បាប់របស់គេហើយ មានន័យថាអាជីវកម្មរបស់ពួកគេបានចុះបញ្ជីត្រឹមត្រូវ(សូមមើលតារាងទី៤)។ បែបនេះ គេមិនអាចគណនាចំណែកពិតប្រាកដនៃផលិតផលជាតិសរុបក្នុងស្រុកដែល MSMEs បានចូលរួមចំណែកសម្រាប់កម្ពុជាទេ។

**តារាងទី៤៖ ចំនួនសហគ្រាសតាមទំហំនិងការចុះបញ្ជី (គិតជាភាគរយ)**

| | សហគ្រាសធុនធំ | សហគ្រាសធុនមធ្យមនិងតូច | មីក្រូសហគ្រាស |
|---|---|---|---|
| ចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម (a) | ៨០,៧ | ៣៣,២ | ១,២ |
| ចុះបញ្ជីនៅក្រសួងផ្សេងៗ (b) | ១៦,៥ | ៤១,៤ | ៤,២ |
| ចុះបញ្ជីនៅក្រសួង (a) និង (b) | ៩៧,២ | ៧៤,៦ | ៥,៤ |
| មិនមានចុះបញ្ជី | ២,៨ | ២៥,៤ | ៩៤,៦ |
| **សរុប** | ០,២ | ២,២ | ៩៧,៦ |

(ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ ៖ ការអង្កេតចន្លោះសេដ្ឋកិច្ចកម្ពុជា ២០១៤, ភ្នំពេញ ២០១៥)

ក្នុងទិដ្ឋភាពទូទៅ កម្ពុជាស្ថិតក្នុងលំដាប់លេខរៀងទី៩៤ភាពប្រកួតប្រជែងនិង(វៀតណាមទី៥៥ និងឡាវទី៩៨) នៅឆ្នាំ ២០១៧-២០១៨ ក្នុងចំណោមប្រទេសចំនួន១៣៧[8]។ សម្រាប់ MSMEs ដោយមានបញ្ហាប្រឈមដូចខាងក្រោម៖

- **ការចុះបញ្ជីប្រើរយៈពេលយូរនិងមានតម្លៃខ្ពស់**

---

[7] National Institute of Statistics: Cambodia Inter-censal Economic Survey 2014, Phnom Penh 2015.
[8] World Economic Forum: The Global Competitiveness Report 2017-2018, Geneva, 2017

កម្ពុជាស្ថិតនៅក្នុងដំណាក់កាលនៃការបង្កើតច្បាប់និងបទបញ្ញាសម្រាប់ចុះបញ្ជី និងឈរនៅលេខរៀងទី ១៣៥ ឯណោះក្នុងចំណោម ១៩០ប្រទេស ដោយរាប់ចាប់ពីការចុះបញ្ជីក្រុមហ៊ុនអាជីវកម្ម រហូតដល់យន្តការពង្រឹងការអនុវត្តកិច្ចសន្យា។ នេះជាចំណាត់ថ្នាក់ចេញពីធនាគារពិភពលោកនៅខែតុលា ឆ្នាំ២០១៨។ ហេតុដូច្នេះហើយបានជា MSMEs មួយចំនួនបានធ្វើប្រតិបត្តិការដោយពុំមានការចុះបញ្ជី។ ភាគច្រើននៃមីក្រូសហគ្រាស ដូចជាអ្នកលក់ និងផ្តល់សេវាចល័ត ប្រតិបត្តិការក្រៅផ្លូវការ ធ្វើឱ្យរាជរដ្ឋាភិបាលមានការលំបាកក្នុងការប្រមូលពន្ធ និងផ្តល់ការគាំទ្រដល់អ្នកទាំងនោះ។ លើសពីនេះទៅទៀតមីក្រូសហគ្រាសទោះបានចុះបញ្ជីក្តី មិនបានចុះបញ្ជីក្តី ស្ថិតនៅក្នុងការប្រកួតប្រជែងដើម្បីដណ្តើមអតិថិជនជាមួយគ្នា។ ចំពោះអ្នកបានចុះបញ្ជីហើយ គឺជារឿងមិនស្មើភាព ហើយខាតបង់ការចំណាយទៀតផង។

- **កង្វះខាតគោលនយោបាយនិងទីផ្សារច្បាស់លាស់**

ទោះជា MSMEs ជាឆ្អឹងខ្នងសម្រាប់កំណើនសេដ្ឋកិច្ចក៏ពិតមែន តែរាជរដ្ឋាភិបាលកម្ពុជានៅមិនទាន់ស្ថាប័នណាមួយច្បាស់លាស់ទេ។ អនុគណៈកម្មាធិការសហគ្រាសធុនតូចនិងមធ្យមបានបង្កើតក៏ពិតមែន តែសិទ្ធិអំណាចក្នុងការបំពេញការងារ ហាក់ដូចជាមានដែនកំណត់ ទាំងធនធានមនុស្ស ទាំងធនធាន សម្ភារៈ ព្រោះគ្រាន់តែជាផ្នែកមួយនៃក្រសួងឧស្សាហកម្មនិងសិប្បកម្មប៉ុណ្ណោះ។ ផែនការយុទ្ធសាស្ត្រដោយឡែកសម្រាប់ MSMEs មិនទាន់មានទេ តែមានផែនការយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍវិស័យឧស្សាហកម្មជារួម ហើយមានផ្នែកខ្លះសម្រាប់អភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យមប៉ុណ្ណោះ។ ក្រសួងជំនាញផ្សេងទៀត មានផែនការយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍសម្រាប់អភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យមរៀងៗខ្លួន។ ដោយសារការគ្រប់គ្រង MSMEs មិនទាន់មានភាពច្បាស់លាស់ MSMEs ភាគច្រើនអាចបញ្ជូនទំនិញរបស់ខ្លួនបានត្រឹមតែទីផ្សារក្នុងស្រុកប៉ុណ្ណោះ។ យោងតាមចំណាត់ថ្នាក់របស់ធនាគារពិភពលោក សម្រាប់ឆ្នាំ២០១៨ កម្ពុជាស្ថិតនៅលេខរៀងទី១០៨ ក្នុងចំណោម១៩០ប្រទេសក្នុងការបញ្ជូនទំនិញទៅលក់នៅបរទេស។

- **លទ្ធភាពទទួលបានហិរញ្ញវត្ថុ**

កម្ពុជាបានពង្រឹងប្រព័ន្ធព័ត៌មានឥណទានរបស់ខ្លួនតាមរយៈការអនុញ្ញាតឱ្យមានការិយាល័យឥណទានតាំងពីឆ្នាំ២០១២ ដើម្បីប្រមូលនិងចែកចាយព័ត៌មានឥណទានទាំងវិជ្ជមានទាំងវិជ្ជមាន។ សម្រាប់ឆ្នាំ ២០១៨ ធនាគារពិភពលោកបានចាត់ចំណាត់ថ្នាក់កម្ពុជាជាប្រទេសទី២០ក្នុងចំណោមប្រទេសចំនួន១៩០។

- **ការអភិវឌ្ឍន៍ធនធានមនុស្ស**

កម្លាំងពលកម្មរបស់កម្ពុជាជាទូទៅខ្វះខាតនូវជំនាញទន់ និងជំនាញរឹង ដើម្បីធ្វើការប្រកួតប្រជែងនៅក្នុងតំបន់។ ការអប់រំវិជ្ជាជីវៈនិងការអភិវឌ្ឍជំនាញក៏មានកម្រិតផងដែរ។

- **តម្លៃផលិតកម្មខ្ពស់:**

បើប្រៀបធៀបទៅនឹងបណ្តាប្រទេសអាស៊ានដទៃទៀត ថ្លៃដើមផលិតកម្មនៅកម្ពុជាមានកម្រិតខ្ពស់។ ភាពងាយស្រួលដើម្បីធ្វើអាជីវកម្មត្រូវបានកែលំអ តែហាក់ដូចជានៅយឺតយ៉ាវ។ តម្លៃអគ្គិសនីគឺស្ថិតក្នុងចំណោមតម្លៃថ្លៃជាងគេបំផុតនៅបណ្តាប្រទេសអាស៊ាន។

- **កង្វះចំណេះដឹងស្តីអំពីការទទួលយកបច្ចេកវិទ្យា**

MSMEs ភាគច្រើនប្រកាន់ខ្ជាប់វិធីសាស្ត្រនៃផលិតតាមបែបធម្មតា។ ម្ចាស់ឬអ្នកគ្រប់គ្រង MSMEs ភាគច្រើនដឹងថា បច្ចេកវិទ្យាថ្មី អាចជួយធ្វើឱ្យប្រសើរឡើងផលិតភាពការងាររបស់គេ។ ក៏ប៉ុន្តែដោយហេតុថាការអប់រំនិងថវិការបស់គេនៅមានកម្រិត នាំឱ្យពួកគេហាក់ដូចជាមិនហ៊ានទទួលយកបច្ចេកវិទ្យាថ្មីទេ។

## សន្និដ្ឋាន

ការធ្វើចំណាត់ថ្នាក់ MSMEs នៅកម្ពុជាមិនទាន់បានសម្រេចនៅឡើយទេ។ អ្វីដែលមានបច្ចុប្បន្ននេះ គ្រប ដណ្តប់តែវិស័យឧស្សាហកម្មនិងសិប្បកម្មប៉ុណ្ណោះ។ សម្រាប់គោលបំណងស្ទង់មតិឬជំរឿននេះ ខណៈពេលដែលគ្មានជំរើសផ្សេងទៀតនោះ វិទ្យាស្ថានជាតិស្ថិតិប្រើចំណាត់ថ្នាក់ដែលមានសម្រាប់តែវិស័យសិប្បកម្មនិងឧស្សាហកម្មសម្រាប់គ្រប់វិស័យផ្សេងទៀតដែរ។ ការធ្វើដូច្នេះលទ្ធផលនៃជំរឿនឬការស្ទង់មតិគឺមិនច្បាស់លាស់ទេព្រោះឧទាហរណ៍តម្រូវការរបស់កម្មករក្នុងវិស័យសិប្បកម្មមានទំហំធំជាងវិស័យបច្ចេកវិទ្យាព័ត៌មាន។

ម្យ៉ាងទៀតជំរឿនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាជារឿយៗមិនរាប់បញ្ចូលមីក្រូសហគ្រាសដែលមានចំនួនច្រើនលើសលុបនោះទេ ឧទាហរណ៍ដូចជាអ្នកលក់ចល័ត អ្នកផ្តល់សេវាដឹកជញ្ជូនជាដើម ។ ជាក់ស្តែងមីក្រូសហគ្រាសទាំងនោះ រួមចំណែកយ៉ាងសកម្មដល់កំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ត្រូវបានដកចេញពីជំរឿន មានន័យថាលទ្ធផលនៃការងាររបស់ពួកគេគឺគ្រាន់តែជាការប៉ាន់ស្មានឬដកចេញប៉ុណ្ណោះ។ សម្រាប់ការសិក្សានាពេលអនាគតលើ MSMEs មានតែទិន្នន័យដែលមិនអាចទុកចិត្តបានតែប៉ុណ្ណោះ។

ការសិក្សាអំពី MSMEs នៅកម្ពុជាភាគច្រើនត្រូវបានធ្វើឡើងដោយអង្គការឯកជនសម្រាប់គោលបំណងវិនិយោគប៉ុណ្ណោះលើកលែងតែមួយចំនួនតូចពី ERIA និងការជំរឿនរបស់វិទ្យាស្ថានជាតិស្ថិតិ។ សម្រាប់ការគ្រប់គ្រងនិងការអភិវឌ្ឍន៍ MSMEs ទាំងមូលមិនទាន់មានទេ ហើយកិច្ចសហប្រតិបត្តិការជាមួយបរទេសក៏លំបាកនឹងកើតមានដែរ។

## គន្ថនិទ្ទេស


១- រាជរដ្ឋាភិបាលកម្ពុជា៖ អនុក្រឹត្យលេខ១៧អនក្រ.បក ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារចំពោះការចុះបញ្ជីដោយស្ម័គ្រចិត្តរបស់សហគ្រាសធុនតូចនិងសហគ្រាសធុនមធ្យម។

២- រាជរដ្ឋាភិបាលកម្ពុជា៖ អនុក្រឹត្យលេខ១២៤ ១២៤អនក្រ.បកចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១៨ស្តីពី ស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារ សម្រាប់សហគ្រាសធុនតូចនិងមធ្យមក្នុងវិស័យអាទិភាព

៣- ACLEDA Bank Lao: Annual Report 2017.

៤- Asian Development Bank, Asia SME finance monitor 2014. Philippines 2015

៥- Baily, P. (2008): Cambodian Small and Medium Sized Enterprises, Constraints, Policies and Proposals for Their Development. In: Lim, H.(ed.), SME in Asia and Globalization, ERIA Research Project Report 2007

៦- Uchikawa Shuji and Souknilanh Keola: Small and Medium Enterprises in Cambodia, Laos and Vietnam. In Kuchiki, A. and S. Uchikawa (eds.). Research on Development Strategy for CLMV Countries, ERIA Research Project Report 2008-5. Pp.237-273. Jakarta: ERIA.

៧- World Economic Forum: The Global Competitiveness Report 2017-2018, Geneva, 2017

៨- World Bank: Doing Business 2018 Reforming to crete jobs, Washington, 2018

៩- https://www.unescap.org/sites/default/files/7 - SMEs IN ASIA AND THE PACIFIC.pdf. Retrieved on 06-09-2018.

១០- http://news.ctv8.com.kh/2018/60438/ . Retrieved on 18-09-2018

១១- https://vietnam.vnanet.vn/khmer/%E1%9E%9F%E1%9E%A0%E1%9E%82%E1%9F%92%E1%9E%9A%E1%9E%B6%E1%9E%9F%E1%9E%9C%E1%9F%80/373435.html. Retrieved on 20-09-2018